**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ២០២៥

**សូមផ្ញើជូន**

**ឯកឧត្តម PHUMTHAM WECHAYACHAI ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រថៃ**

(រាជធានីបាងកក)

ឯកឧត្តម ជាទីរាប់អាន!

ខ្ញុំមានសេចក្តីសោកស្តាយយ៉ាងក្រៃលែង ក្រោយពីបានទទួលដំណឹងអំពីការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ ដែលបណ្តាលមកពីគ្រោះរញ្ជួយដីកម្រិតខ្ពស់នៅទីក្រុងបាកក នៃព្រះរាជាណាចក្រថៃ ដែលបានធ្វើឱ្យប្រជាជនរងរបួស និងបាត់បង់អាយុជីវិតជាច្រើននាក់ បានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធនានា រួមទាំងការខូចខាតទ្រព្យសម្បត្តិ និងធ្វើឱ្យបាត់បង់ទីលំនៅរបស់ប្រជាជនជាច្រើនគ្រួសារ។

តាងនាមឱ្យនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំបំផុត និងសោកស្តាយជាពន់ពេក ជាមួយប្រជាជន នៃព្រះរាជាណាចក្រថៃ តាមរយៈឯកឧត្តម ជូនចំពោះគ្រួសារ នៃជនរងគ្រោះចំពោះការបាត់បង់សមាជិកគ្រួសារជាទីស្រលាញ់ និងអ្នករងគ្រោះដោយគ្រោះរញ្ជួយដីដ៏ធំនេះ។

សមានចិត្ត និងការបួងសួងរបស់យើងខ្ញុំស្ថិតនៅជាមួយឯកឧត្តម នៅក្នុងគ្រាដ៏លំបាកនេះ និងសូមឧទ្ទិសឱ្យដួងវិញ្ញាណក្ខន្ធអ្នកបាត់បង់ជីវិត បានទៅកាន់សុគតិភព និងសូមជូនពរអ្នករងរបួសឆាប់ជាសះស្បើយឡើងវិញក្នុងពេលឆាប់ៗខាងមុខនេះ។ ខ្ញុំជឿជាក់ថា នឹងមានការកសាង និងស្តារឡើងវិញឆ្ពោះទៅរកប្រក្រតីភាពយ៉ាងឆាប់រហ័ស នៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយគ្រោះមហន្តរាយនេះ។

សូម **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រថៃ** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**